**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស(អបជ ) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | ខ្មែរ |

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jul-21, 15:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** **សាធារណៈ/Public**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យមិនបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Olivier BEAUVALLET
ចៅក្រម BAIK Kang Jin

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៣**

**សហមេធាវី មាស មុត:**
អាង ឧត្តម
Michael KARNAVAS

## I. សេចក្តីផ្តើម

1. កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនកាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣[1] ទៅអង្គបុរេជំនុំជម្រះ ដោយបានស្នើសុំ៖

ក- បិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង០០៣ ដោយការផ្តល់នូវការសម្រេចជាស្ថាពរមួយដែលឯកភាពគ្នា ដែលបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់ និងបង្គាប់ឱ្យនាំខ្លួនគាត់ទៅជំនុំជម្រះ និង

ខ- ចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវសេចក្តីពិចារណាដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៣ និងសំណុំរឿងដែលនៅសេសសល់ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

2. សហព្រះរាជអាជ្ញាជាតិសូមធ្វើការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនកាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[2] ដោយបានសម្រេចជាឯកច្ឆន្ទថា៖ ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក និងប្រកាសថា៖ អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រម បួនរូបយ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសម្អាងហេតុរួមមួយបានឡើយ។ សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

4. ដោយសារអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រម បួនរូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីបាន **ចៅក្រមជាតិ** នៃអង្គបុរេជំនុំជម្រះ បានសម្រេចបញ្ជូនសំណុំរឿង ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។

---

[1] ឯកសារ **D271/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣។

[2] ឯកសារ **D266/27** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះ។

5. ដោយសារអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រម បួនរូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីបាន **ចៅក្រមអន្តរជាតិ** នៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកសំណុំរឿង ០០៣ មកពិនិត្យ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង។

6. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[3]។

7. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេត បានសម្រេចសេចក្តីលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[4]។

8. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងបន្ទាន់ទៅកាន់សហចៅក្រមស៊ើបអង្កេត អំពីបំណងរបស់ខ្លួនក្នុងការដាក់ការឆ្លើយតបលើបញ្ហាទាក់ទងនឹងការបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង[5]។

9. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីសម្រេចបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ការឆ្លើយតប[6]។

10. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ មេធាវីការពារក្តីរបស់ មាស មុត បានដាក់សំណើសុំពន្យារពេលចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣[7]។

---

[3] ឯកសារ **D270** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

[4] ឯកសារ **D270/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង។

[5] ឯកសារ **D270/5** ការជូនដំណឹងបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបំណងក្នុងការដាក់ការឆ្លើយតបលើបញ្ហាទាក់ទងនឹងការបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុជម្រះសាលាដំបូង។

[6] ឯកសារ **D270/6** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ការឆ្លើយតប។

[7] ឯកសារ **D271/2** សំណើរបស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួន តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៣។

11. នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ បានជូនដំណឹងតាមរយៈសារអេឡិចត្រូនិត អនុញ្ញាតឱ្យភាគីនានាក្នុងសំណុំរឿង ០០៣ អាចដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅត្រឹមបញ្ចប់ម៉ោងធ្វើការថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១។

## III. សេចក្ដីសន្និដ្ឋាន

12. យោងតាមការសម្រេចរបស់ **ចៅក្រមជាតិ** នៃអង្គបុរេជំនុំជម្រះ ដែលបានសម្រេចបញ្ជូនសំណុំរឿង ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។

13. នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ មេធាវីការពារក្ដី មាស មុត បានដាក់សំណើជាភាសាអង់គ្លេសទៅអង្គបុរេជំនុំជម្រះ សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលក្នុងបណ្ណសារនូវសំណុំរឿង ០០៣[8]។

14. ដោយសារសំណុំរឿងលេខ ០០៣ មានលក្ខណៈដូចគ្នានឹងសំណុំរឿងលខ ០០៤/២ ជាពិសេសត្រង់ចំណុចសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានសម្រេចជាឯកច្ឆន្ទថា៖ “ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ហើយអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រមបួនរូប យ៉ាងតិច ដើម្បីចេញសេចក្ដីសម្រេចបាន”។

15. ក្នុងសំណុំរឿងលេខ ០០៤/២ ដែលមានជនត្រូវចោទ អោ អាន កន្លងមក អង្គបុរេជំនុំជម្រះសម្រេចមិនឱ្យក្រឡាបញ្ជីរបស់ខ្លួនបញ្ជូនសំណុំរឿងនេះឡើយ។

16. យោងតាមសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតពីមុន ដែលជាយុត្តិសាស្ត្រ ក្នុងសំណុំរឿង ០០៤/២ ដែលមានជនត្រូវចោទ អោ អាន បានសម្រេចបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ[9]។

---

[8] ឯកសារ **D272** សំណើរបស់ មាស មុត ទៅអង្គបុរេជំនុំជម្រះ សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលក្នុងបណ្ណសារនូវសំណុំរឿង ០០៣ ។

[9] ឯកសារ **D363/3** ដីកាបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ របស់សហចៅក្រមស៊ើបអង្កេត។

17. ដូចសេចក្តីថ្លែងការណ៍ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន បានគូសបញ្ជាក់ច្បាស់ថា នឹងពុំមានការជំនុំជម្រះលើសំណុំរឿង ០០៤/២ នៅពេលនេះ ឬនៅពេលអនាគតឡើយ។

18. សរុបមក សហព្រះរាជអាជ្ញាជាតិ ជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនកាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ និងបញ្ជូនទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

19. សហព្រះរាជអាជ្ញាជាតិស្នើសុំអង្គបុរេជំនុំជម្រះ មេត្តាអនុវត្តតាមខ្លឹមសារវិធាន ៦៩ ចំណុច ២ (ខ) នៃវិធានផ្ទៃក្នុង ដែលបានចែងថា "ប្រសិនបើមានដីកាលើកលែងចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ"។

## IV. ដំណោះស្រាយដែលបានស្នើសុំ

20. ចំពោះមូលហេតុនានាដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាជាតិស្នើថា អបជ គួរ៖

ក. សម្រេចបញ្ចប់នីតិវិធីសំណុំរឿង ០០៣។

ខ. សម្រេចបោះគ្រាសំណុំរឿង ០០៣ និង

គ. សម្រេចដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ អ.វ.ត.ក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature and stamp] |